# THE STEPHEN PHILLIPS
# មូលនិធិអាហារូបករណ៍អនុស្សាវរីយ៍

## អំពីអាហារូបករណ៍

**មូលនិធិអាហារូបករណ៍អនុស្សាវរីយ៍ The Stephen Phillips**
**ផ្តល់ជូននូវអាហារូបករណ៍ដែលអាចបន្តរាល់ឆ្នាំរហូតដល់រយៈពេល 4ឆ្នាំ ដល់សិស្សដែលមានតម្រូវការហរិញ្ញវត្ថុ ដែលបង្ហាញអោយឃើញពីលទ្ធផលដែលធ្វើបានសម្រេចក្នុងកម្មវិធីសិក្សាមានការតាំងចិត្តខ្ពស់ក្នុងការជួយអ្នកដទៃ (ក្នុងសាលា ក្នុងសហគមន៍ ឬនៅផ្ទះ) ប្រវត្តិការងារក្រៅម៉ោងដែលមិនផ្លាស់ប្តូរ បង្ហាញអោយឃើញពីភាពចាស់ទុំ និងជំនាញផ្សេងៗពេលប្រឈមមុខជាមួយបញ្ហា និងមានលក្ខណៈសម្បត្តិជាអ្នកដឹកនាំ។**

- ✓ បេក្ខជនអាចចូលរៀនមហាវិទ្យាល័យណាមួយក៏បានក្នុងសហរដ្ឋអាមេរិច ប៉ុន្តែត្រូវតែមកពីរដ្ឋ New England.
- ✓ អាហារូបករណ៍គឺផ្តល់ជូនចំពោះតែសិស្សដែលចង់រៀនកំរិតបរិញ្ញាបត្រលើកទីមួយរបស់ពួកគេនៅមហាវិទ្យាល័យរយៈពេល 4ឆ្នាំតែប៉ុណ្ណោះ។
  *សិស្សថ្នាក់ទី12នៅវិទ្យាល័យ ឬសិស្សដែលមានបំណងចង់រៀននៅមហាវិទ្យាល័យ ឬសិស្សដែលកំពុងតែរៀននៅមហាវិទ្យាល័យ បច្ចុប្បន្ន ចូលរៀនមហាវិទ្យាល័យពេញម៉ោងក្នុងឆ្នាំសិក្សា 2024-25.*
- ✓ បេក្ខជនត្រូវមានមធ្យមភាពពិន្ទុ GPA 3.0 ឬខ្ពស់ជាង សម្រាប់មធ្យមភាពពិន្ទុសរុប 4.0។
- ✓ សិស្សគួរតែចូលរួមសេវាកម្មសហគមន៍ និងមានប្រវត្តិការងារក្រៅម៉ោង។
- ✓ បេក្ខជនត្រូវតែមានតម្រូវការហរិញ្ញវត្ថុ។ មុនការចាប់ផ្តើមដាក់ពាក្យបេក្ខជនគួរតែប្រើកម្មវិធីគណនាហិរញ្ញវត្ថុដែលមាននៅលើគេហទំព័ររបស់ the Phillips ដើម្បីអោយប្រាកដថាពួកគេមានលក្ខណៈគ្រប់គ្រាន់ផ្នែកហិរញ្ញវត្ថុដែរឬទេ។
  *វាជាចេតនារបស់ពួកយើងក្នុងការផ្តល់ប្រាក់រង្វាន់ដល់សិស្សជាមួយសន្ទស្សន៍ជំនួយសិស្ស (SAI) ចំនួន $13,000 ឬតិចជាង។ ទោះបីជាគ្រួសារដែលមានស្ថានភាពហរិញ្ញវត្ថុពិសេសៗ គួរតែទូរស័ព្ទ ឬផ្ញើសារអេឡិចត្រូនិចមក ដើម្បីអោយដឹងថាពួកគេអាចដាក់ពាក្យបានដែរឬទេ។ តម្រូវការហរិញ្ញវត្ថុរបស់សិស្សម្នាក់ គឺជាការចាត់ទុកអាហារូបករណ៍ និងប្រាក់រង្វាន់ក្នុងការផ្តល់ជូនរង្វាន់ ផ្នែកហរិញ្ញវត្ថុរបស់ពួកគេ ដូច្នេះសិស្សត្រូវការពត៌មាននេះដើម្បីគណនាតម្រូវការរបស់ពួកគេ។ 84% នៃសិស្សដែលត្រូវបានផ្តល់អាហារូបករណ៍ក្នុងឆ្នាំ 2023 ឪពុកម្តាយពួកគេមានប្រាក់ចំណូលសរុបប្រចាំឆ្នាំតិចជាង $85,000.*
- ✓ បេក្ខជនត្រូវតែជាជនជាតិអាមេរិក ឬមិនមែនជនជាតិអាមេរិកប៉ុន្តែមានសិទ្ធិរស់នៅស្របច្បាប់នាពេលបច្ចុប្បន្ន និងមានសិទ្ធិស្របច្បាប់ធ្វើការក្នុងសហរដ្ឋអាមេរិក។

## របៀបក្នុងការដាក់ពាក្យ

សូមចូលទៅកាន់គេហទំព័រ **www.phillips-scholarship.org**
សម្រាប់ពត៌មានបន្ថែមអំពីការដាក់ពាក្យដើម្បីទទួលបាន អាហារូបករណ៍ និងដើម្បីអាចចូលទៅដល់ទំរង់បែបបទក្នុងការដាក់ពាក្យរបស់អាហារូបករណ៍។
**បេក្ខជនត្រូវតែបំពេញទំរង់បែបបទទទួល អាហារូបករណ៍តាមប្រព័ន្ធអ៊ីនធើណេត។**
ការដាក់ពាក្យតាមសំបុត្រគឺមិនយកជាផ្លូវការឡើយ។ ចាប់ផ្តើមការដាក់ពាក្យតាមប្រព័ន្ធអ៊ិនធើណេតអោយបានលឿនដើម្បីបញ្ជាក់ពីការហួតចត់ក្នុងការឆ្លើយតបរបស់អ្នក និងដើម្បីអោយអ្នកណែនាំមានពេលក្នុងការឆ្លើយតប សំណើររបស់អ្នក។ របាយការណ៍នៃបេក្ខជនភាគច្រើន គឺត្រូវចំណាយពេលពី 1ម៉ោង ទៅ 6ម៉ោង ដើម្បីបំពេញ ទំរង់នៃការដាក់ពាក្យ។ ដើម្បីបំពេញទំរង់នៃការដាក់ពាក្យ អ្នកត្រូវតែផ្ញើ:



- ✓ សំណេរផ្លូវការមួយ និងការឆ្លើយតបខ្លីៗពីរឬបី
- ✓ ពត៌មានអំពីរង្វាន់ជំនួយហិរញ្ញវត្ថុពីមហាវិទ្យាល័យ ឬសកលវិទ្យាល័យដែលអ្នកមានគម្រោងចង់ចូលរៀន
- ✓ ពត៌មានលំអិតពីឈ្មោះ និងទំនាក់ទំនងរបស់អ្នកណែនាំយ៉ាងហោចណាស់ម្នាក់
- ✓ សេចក្តីសង្ខេបនៃការស្នើសុំជំនួយហរិញ្ញវត្ថុសហព័ន្ធរបស់អ្នក(FSS)

**ថ្ងៃផុតកំណត់ធម្មតា– 12 ថ្ងៃត្រង់, ថ្ងៃទី1 ខែឧសភា , 2024.**
*បេក្ខជននឹងត្រូវបានជូនដំណឹងពីលទ្ធផលនៅចុងខែមិថុនា។*

**ថ្ងៃផុតកំណត់នៃការឆ្លើយតបលឿន – 12 ថ្ងៃត្រង់ ថ្ងៃទី3 ខែមេសា, 2024.**
*សម្រាប់តែសិស្សវិទ្យាល័យដែលមានពត៌មានហរិញ្ញវត្ថុពីមហាវិទ្យាល័យដែលពួកគេចង់ចូលរៀន។ សិស្ស 400 នាក់ដំបូងដែលបាន ផ្ញើទំរង់នៃការដាក់ពាក្យមុនថ្ងៃទី 3 ខែមេសា នឹងដឹងពីលទ្ធផលមុនការឆ្លើយតបធម្មតានៅថ្ងៃទី1 ខែឧសភា។*

**ទំរង់ W-2 សិស្ស 2023** និង **ទំរង់ពន្ធឪពុកម្តាយ 2022.**
*ទំរង់ទាំងនេះអាចនឹងត្រូវបានធ្វើការស្នើសុំនៅក្នុងដំណើរការបន្ទាប់.*

**THE STEPHEN PHILLIPS MEMORIAL SCHOLARSHIP FUND, INC.**
PO Box 870 • SALEM MA 01970
www.phillips-scholarship.org • staff@spscholars.org • 978-744-2111